ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
******

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
******

## ឯកឧត្តម ទេសរដ្ឋមន្ត្រី ប្រាក់ សុខុន ទទួលជួប ឯកឧត្តម Tomas Kuchta អនុរដ្ឋមន្ត្រីការពារប្រទេស នៃសាធារណរដ្ឋឆែក

******

នៅព្រឹកថ្ងៃទី ០៨ ខែ**វិច្ឆិកា** ឆ្នាំ**២០១៧** វេលាម៉ោង១០:០០ នៅទីស្តីការក្រសួង ឯកឧត្តម **ប្រាក់ សុខុន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានអនុញ្ញាតអោយគណៈប្រតិភូក្រសួងការពារប្រទេសរបស់សាធារណរដ្ឋឆែក ដឹកនាំដោយឯកឧត្តម Tomas Kuchta អនុរដ្ឋមន្ត្រីការពារប្រទេស អមដំណើរដោយ ឯកឧត្តម Marek Libricky ឯកអគ្គរដ្ឋទូតរបស់ឆែកប្រចាំនៅព្រះរាជាណាចក្រកម្ពុជា មាននិវេសនដ្ឋាននៅទីក្រុងបាងកក ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានសំដែងនូវការស្វាគមន៍យ៉ាងកក់ក្តៅចំពោះដំណើរទស្សនកិច្ចរបស់គណៈប្រតិភូ និងបានរំលឹកឡើងវិញពីទំនាក់ទំនងជាពិសេសដ៏យូរលង់និងជិតដិតរវាងប្រទេសទាំងពីរ ពិសេសគឺទំនាក់ទំនងដែលបានផ្សារភ្ជាប់រវាងព្រះករុណា**ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាមួយនឹងសាធារណរដ្ឋឆែក។ **ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏បានវាយតម្លៃខ្ពស់ចំពោះការជួយឧត្តម្ភរបស់ឆែកចំពោះកម្ពុជា នៅក្នុងដំណាក់កាលដែលកម្ពុជាជួបនូវការលំបាកយ៉ាងខ្លាំង បន្ទាប់ពីការរំដោះប្រទេសជាតិពីរបបប្រល័យពូជសាសន៍ខ្មែរក្រហម ហើយនិងទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ រហូតមកដល់ពេលបច្ចុប្បន្ននេះ ពិសេសគឺនៅលើវិស័យអប់រំ កសិកម្ម ថាមពល បច្ចេកវិទ្យាការពារប្រទេស។ល។

**ឯកឧត្តមអនុរដ្ឋមន្ត្រីការពារប្រទេសឆែក** បានវាយតម្លៃខ្ពស់ចំពោះទំនាក់ទំនងដ៏ជិតស្និទ្ធរវាងប្រទេសទាំងពីរ ហើយឯកឧត្តមបានអះអាងថា ដំណើរទស្សនកិច្ចរបស់ឯកឧត្តមមកកាន់ព្រះរាជាណាចក្រកម្ពុជានៅពេលនេះ គឺសំដៅពង្រឹងបន្ថែមទៀតនូវភាពជាដៃគូរវាងប្រទេសទាំងពីរ ហើយនិងពិភាក្សាស្វែងរកវិធីដើម្បីលើកស្ទួយបន្ថែមទៀតនូវទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការ ហើយនិងការផ្លាស់ប្តូរពាណិជ្ជកម្មរវាងប្រទេសទាំងពីរនេះ។ **ឯកឧត្តម** ក៏បានលើកឡើងផងដែរអំពីបំណងរបស់ប្រទេសឆែក ក្នុងការបង្កើតអោយមានកិច្ចសហប្រតិបត្តិការក្នុងពេលអនាគត នៅលើផ្នែកគ្រប់គ្រងទឹកស្អុយ (waste water management) ថាមពលពន្លឺព្រះអាទិត្យ ធនធានរ៉ែ និងបច្ចេកវិទ្យាការពារជាតិ ហើយគំនិតផ្តើមនេះ ត្រូវបានកម្ពុជាស្វាគមន៍។

**ឯកឧត្តមអនុរដ្ឋមន្ត្រី** បានគូសបញ្ជាក់ថា កម្ពុជាត្រូវបានរដ្ឋាភិបាលរបស់ប្រទេសឆែក ចាត់ទុកជាប្រទេសមួយក្នុងចំណោមប្រទេសអាទិភាព៦ ក្នុងយុទ្ធសាស្ត្រកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍របស់ប្រទេសឆែក

សម្រាប់រយៈកាលឆ្នាំ**២០១៨** ដល់**២០២០**។ ផ្តើមចេញពីនេះ រដ្ឋាភិបាលឆែកយកចិត្តទុកដាក់ក្នុងការជម្រុញកិច្ចសហប្រតិបត្តិការខាងផ្នែកសេដ្ឋកិច្ច និងទំនាក់ទំនងលើផ្នែកធុរៈកិច្ចរវាងប្រទេសទាំងពីរ។ ក្នុងន័យនេះ ទស្សនកិច្ចរបស់ឯកឧត្តម ត្រូវបានអមដំណើរដោយក្រុមហ៊ុនរបស់ប្រទេសឆែកចំនួន៨ក្រុមហ៊ុន ដើម្បីពិនិត្យអំពីលទ្ធភាពក្នុងការជម្រុញទំនាក់ទំនងខាងលើនេះ។ **គណៈប្រតិភូ** ក៏បានជម្រាបជូន **ឯកឧត្តមទេសរដ្ឋមន្ត្រី** ផងដែរ អំពីគម្រោងរបស់រដ្ឋាភិបាលឆែក ក្នុងការបញ្ជូនគណៈប្រតិភូមួយរបស់សភាពាណិជ្ជកម្ម មកកាន់កម្ពុជា នៅក្នុងឆ្នាំក្រោយនេះ ដើម្បីធ្វើការពិភាក្សាជាមួយសភាពាណិជ្ជកម្មនិងធុរកិច្ចជនរបស់កម្ពុជាលើការងារនេះ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានសម្តែងនូវអំណរគុណចំពោះរដ្ឋាភិបាលឆែក ដែលបានចាត់ទុកកម្ពុជាជាប្រទេសមួយនៅក្នុងចំណោមប្រទេសអាទិភាពសម្រាប់កិច្ចសហប្រតិបត្តិការ ហើយ **ឯកឧត្តមទេសរដ្ឋមន្ត្រី** និង **ឯកឧត្តមអនុរដ្ឋមន្ត្រី** បានសំដែងនូវការរីករាយពេញចិត្តចំពោះការកើនឡើងយ៉ាងខ្លាំងនូវការផ្លាស់ប្តូរពាណិជ្ជកម្មរវាងប្រទេសទាំងពីរ គឺពី**២៨លានដុល្លារ** ក្នុងឆ្នាំ២០១៤ ដល់**១៧០លានដុល្លារ** នៅក្នុងឆ្នាំ២០១៦។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏បានអរគុណប្រទេសឆែក ដែលបានផ្តល់អាហារូបករណ៍ជាច្រើនដល់និស្សិតរបស់កម្ពុជាកន្លងមក ហើយបានស្នើសុំឲ្យភាគីឆែកបន្តផ្តល់អាហារូបករណ៍ដល់និស្សិតកម្ពុជាបន្តទៀត។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានសំដែងនូវការរីករាយ ដែលសេចក្តីព្រាងនៃអនុស្សរណៈស្តីពីការពិគ្រោះយោបល់រវាងក្រសួងការបរទេសទាំងពីរ ត្រូវបានឯកភាពដោយភាគីទាំងពីរ ហើយនៅសល់តែការសម្របសម្រួលលើពេលវេលានិងទីកន្លែង ដើម្បីចុះហត្ថលេខាលើអនុស្សរណៈនោះតែប៉ុណ្ណោះ ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានជម្រាបជូន**គណៈប្រតិភូ** អំពីការបង្កើតវិទ្យាស្ថានជាតិការទូតនិងទំនាក់ទំនងអន្តរជាតិ ហើយក៏បានស្នើឲ្យមានកិច្ចសហប្រតិបត្តិការរវាងវិទ្យាស្ថាននេះ ជាមួយនឹងវិទ្យាស្ថានពាក់ព័ន្ធរបស់ប្រទេសឆែក។

**គណៈប្រតិភូ** បានសំដែងនូវការស្វាគមន៍ចំពោះការលើកឡើងរបស់**ឯកឧត្តមទេសរដ្ឋមន្ត្រី** និងបានគូសបញ្ជាក់ថា ប្រទេសឆែករីករាយនឹងពិនិត្យលទ្ធភាពនៃកិច្ចសហប្រតិបត្តិការលើផ្នែកនេះ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏បានសំដែងនូវអំណរគុណចំពោះរដ្ឋាភិបាលឆែក ដែលបានលុបចោលចំនួនប្រមាណ៨០%នៃបំណុលរបស់កម្ពុជាចំពោះឆែក ហើយចំនួនដែលនៅសល់ត្រូវបានរដ្ឋាភិបាលឆែកប្រែក្លាយជាជំនួយអភិវឌ្ឍន៍លើវិស័យផ្សេងៗនៅកម្ពុជា។

នៅក្នុងក្របខ័ណ្ឌនៅក្នុងកិច្ចសហប្រតិបត្តិការលើឆាកអន្តរជាតិ **គណៈប្រតិភូ** បានជំរាបជូន **ឯកឧត្តមទេសរដ្ឋមន្ត្រី** អំពីការសំរេចរបស់រដ្ឋាភិបាលឆែកក្នុងការគាំទ្រចំពោះបេក្ខភាពកម្ពុជាជាសមាជិករបស់ក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គម (ECOSOC) សម្រាប់អាណត្តិឆ្នាំ**២០១៩**។ **ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏បានសំដែងនូវអំណរគុណចំពោះការគាំទ្រនេះ ហើយបានវាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការជួយគាំទ្រគ្នាទៅវិញទៅមករវាងកម្ពុជានិងឆែក លើឆាកអន្តរជាតិ។

**គណៈប្រតិភូ** ក៏បានសម្តែងនូវការអបអរសាទរចំពោះការរីកចម្រើនផ្នែកសេដ្ឋកិច្ចនៅកម្ពុជា ដែលបានអនុញ្ញាតឲ្យកម្ពុជាត្រូវបានតម្លើងកំរិតពីប្រទេសដែលមានចំណូលទាប ទៅជាប្រទេសដែលមានចំណូលមធ្យមកំរិតទាប។ ទាក់ទងនឹងបញ្ហានេះ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានជម្រាបជូនគណៈប្រតិភូថា ការរីកចំរើននេះ គឺអាស្រ័យដោយការខិតខំប្រឹងប្រែងរួមរបស់រាជរដ្ឋាភិបាលនិងប្រជាជនកម្ពុជា ដោយមានការជួយជ្រោមជ្រែងពីបណ្តាមិត្ត ក្នុងនោះមានប្រទេសឆែកផង និងពិសេសដោយសារសន្តិភាពនិងស្ថិរភាពក្នុងស្រុកផង។ មូលហេតុនេះដែលនាំឲ្យរដ្ឋាភិបាលកម្ពុជាប្រកាន់យកនូវវិធានការផ្លូវច្បាប់នានាកន្លងទៅថ្មីៗនេះ ដើម្បីការពារសន្តិភាព ស្ថិរភាព ឯករាជ្យ និងអធិបតេយ្យ។

ជំនួបនេះ បានបញ្ចប់ក្នុងបរិយាកាសរីករាយ និងស្និទ្ធស្នាល។

ភ្នំពេញ, ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ២០១៧